云南日报 YUNNAN DAILY PRESS GROUP 云南日报报业集团 No.116

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7381 ថ្ងៃសុក្រ ទី 14 ខែ កក្កដា ឆ្នាំ 2017

# វេទិកាថាមពលស្អាតលើកទី៣នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាប្រារព្ធនៅក្រុងគុនមីង



ទិដ្ឋភាពនៃវេទិកា (រូបថត ដោយ Han Chengyuan )

***ដោយ ចាំង យូគូ និង ហាន ឈីងយាន់***

ពេលថ្មីៗនេះ វេទិកាថាមពលស្អាតលើកទី៣ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាបានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណានប្រទេសចិន ។

វេទិកានេះរៀបចំក្រោមប្រធានបទ "ពង្រឹងកិច្ចសហប្រតិបត្តិការជាក់ស្តែង ជំរុញការផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក និងការឈ្នះ-ឈ្នះបង្កើតប្រព័ន្ធថាមពលក្នុងតំបន់ ដែលមានពណ៌បៃតងតភ្ជាប់គ្នាផ្តល់ការអនុគ្រោះទូទៅ និងមានលក្ខណៈពិពិធកម្ម" ។មន្ត្រីរាជការ អ្នកជំនាញការ និងតំណាងសហគ្រាសជាង២៧០រូប ដែលមកពីប្រទេស និងអង្គការអន្តរជាតិជាង១០ បានចូលរួមក្នុងវេទិកានេះ ដើម្បីចែករំលែកគ្នា និងផ្លាស់ប្តូរអំពីសមិទ្ធផល និងបទពិសោធន៍នៃការអភិវឌ្ឍថាមពលស្អាតព្រមទាំងពិគ្រោះពិភាក្សាគ្នាអំពីអនាគតនៃថាមពលស្អាត ។

ខេត្តយូនណានជាគំរូឈានមុខក្នុងការអភិវឌ្ឍប្រព័ន្ធកាបូនកម្រិតទាប និងការថែរក្សាអេកូ-បរិស្ថាន ហើយអំពាវនាវឱ្យអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង។ក្រោយពីរដ្ឋាភិបាលចិនលើកឡើងគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ខេត្តយូនណានបានទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងដើម្បីអភិវឌ្ឍន៍វិស័យថាមពល ។ ខេត្តយូនណាននឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីនានាដើម្បីជំរុញការអភិវឌ្ឍនិងប្រើប្រាស់ថាមពលស្អាតបង្កើតនិម្មាបនកម្មថ្មីនៃការអភិវឌ្ឍថាមពលស្អាតដែលមានពណ៌បៃតងតភ្ជាប់គ្នាផ្តល់ការអនុគ្រោះទូទៅនិងមានលក្ខណៈពិពិធកម្ម" ហើយខិតខំជំរុញការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងបុព្វហេតុថែរក្សាការពារ បរិស្ថាននៅតំបន់អាស៊ីបូព៌ា ៕

# សភាពាណិជ្ជកម្មខេត្តហឺប៉េប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាសម្ពោធជាផ្លូវការពេលថ្មីៗនេះ

សភាពាណិជ្ជកម្មខេត្តហឺប៉េប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា បានត្រូវបង្កើតជាផ្លូវការនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ។ សភាពាណិជ្ជកម្មនេះជាអង្គការសង្គមស៊ីវិលមួយ ដែលមិនស្វែងរកចំណេញ ហើយបានទទួលការអនុញ្ញាតឱ្យចុះបញ្ជីនៅក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា ។ សភាពាណិជ្ជកម្មនេះត្រូវបានបង្កើតឡើង ដើម្បីបង្កើនការផ្លាស់ប្តូររវាងខេត្តហឺប៉េ និងប្រទេសកម្ពុជា និងពង្រឹងកិច្ចសហប្រតិបត្តិការសង្គមស៊ីវិលក្រោមក្របខ័ណ្ឌនៃយុទ្ធសាស្ត្រ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។ គួរបញ្ជាក់ថា សហគ្រាសចំនួន៣៦បានចូលជាសមាជិកក្រុមប្រឹក្សានៃសភាពាណិជ្ជកម្មខេត្តហឺប៉េប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាដែលមានពាក់ព័ន្ធនឹងវិស័យសុខាភិបាល អចលនវត្ថុ ភោជនីយដ្ឋាន ពាណិជ្ជកម្មប្រព័ន្ធឡជីស្ទីក និងសណ្ឋាគារជាដើម ។

លោក ឆឹន ស៊ីនហួ ប្រធានសភាពាណិជ្ជកម្មខេត្តហឺប៉េប្រទេសចិនប្រចាំនៅប្រទេសកម្ពុជាបានថ្លែងថា ទន្ទឹមនឹងការអនុវត្តយុទ្ធសាស្ត្រ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" មានសហគ្រាសខេត្តហឺបេ "កាន់តែច្រើនកំពុងតែខិតខំ "ដើរចេញទៅក្រៅ" ។ ប្រទេសកម្ពុជាជាអ្នកជិតខាងល្អរបស់ប្រទេសចិន ហើយក៏ជាទីដៅវិនិយោគសំខាន់របស់សហគ្រាសចិនដែរ ។ ខ្ញុំជឿជាក់ថា សេដ្ឋកិច្ចកម្ពុជានឹងអាចទទួលបានការរីកចម្រើនកាន់តែច្រើនថែមទៀតនាពេលអនាគត ៕

**(អត្ថបទពីវេបសាយសេដ្ឋកិច្ចចិន)**

# សុបិន "AVG" របស់លោកតាមួយរូប

***ដោយ លី ហុងហ្វឹង***

នៅខេត្តយូនណាននៃប្រទេសចិន លោកតា សួន ក្វាន់ស៊ឹង ដែលមានអាយុជាង៧០ឆ្នាំនោះ មានសុបិនមួយតាំងពីយូរមកហើយ។ ពាក្យថា "AVG" គឺឈ្មោះកាត់របស់ "American Volunteer Group" ដែលមានន័យថា "ក្រុមអ្នកបើកយន្តហោះស្ម័គ្រចិត្តអាមេរិក" ។

លោកតា សួន ក្វាន់ស៊ឹង ជាអ្នកកាសែតចាស់មួយរូបនៅខេត្តយូនណាន។ ២០ឆ្នាំមុន លោកបានកើតគំនិតចង់ប្រមូល និងរក្សាទុកឯកសារអំពីក្រុម "AVG" ។ ក្រោយពីចូលនិវត្តន៍ លោកខិតខំយ៉ាងពេញទំហឹងដើម្បីស្វែងរកឯកសារ សម្ភារៈប្រើប្រាស់ និងបំណែកយន្តហោះរបស់ក្រុម "AVG" ព្រមទាំងផ្នូរវីរជនរបស់ក្រុម "AVG" ។

២០ឆ្នាំកន្លងផុតទៅហើយ លោកបានបង្កើតសមាគមសិក្សាស្រាវជ្រាវក្រុម "AVG" ទី១ របស់ប្រទេសចិន ដែលលោកបានដាក់ឈ្មោះថា សមាគមស្រាវជ្រាវ "AVG" នៃខេត្តយូនណាន ។ មិនតែប៉ុណ្ណោះ លោកបានបង្កើតសារមន្ទីរក្រុម "AVG" ទី១ របស់ប្រទេសចិនសាងសង់វិមានរំលឹកវិញ្ញាណក្ខន្ធរបស់វីរបុរស "AVG" ពន្លា "AVG" ព្រមទាំងសរសេរ និងចុះផ្សាយអត្ថបទ និងសៀវភៅច្រើន ដែលមានពាក់ព័ន្ធទៅនឹងក្រុម "AVG" ។ ទាំងនេះបានទទួលការចាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋានក្នុង និងក្រៅប្រទេសចិន ។ មន្ត្រីការទូតប្រទេសអាមេរិកប្រចាំនៅប្រទេសចិនច្រើនរូបធ្លាប់ទៅទស្សនាសារមន្ទីររបស់លោកនៅក្រុងគុនមីងខេត្តយូនណានហើយបានកោតសរសើរ



លោកតា សួន ក្វាន់ស៊ឹង (រូប ស្តាំ) បង្ហាញអ្នកទស្សនាជុំវិញសារ មន្ទីរក្រុម "AVG " ខេត្តយូនណាន (រូបថត ដោយ Li Hongfeng )

និងវាយតម្លៃខ្ពស់ចំពោះការរួមវិភាគទានរបស់លោកក្នុងការបន្តផ្សព្វផ្សាយ និងពង្រឹងចំណងមិត្តភាពចិននិងអាមេរិកនៅសម័យសង្គ្រាមលោកលើកទី២ ។

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់លោកចំណងមិត្តភាពបែប "AVG" រវាងប្រជាជននៃប្រទេសទាំងពីរចិន និងអាមេរិក ដែលត្រូវបង្កើតនៅក្នុងសង្គ្រាមប្រឆាំងនឹងការឈ្លានពានរបស់ពួកហ្វាស៊ីសជប៉ុន បានត្រូវថែរក្សាដាក់តាំងបង្ហាញ និងបន្តផ្សព្វផ្សាយទៅឱ្យកូនចៅជំនាន់ក្រោយ ។

លោក សួន ក្វាន់ស៊ឹង បានឧទ្ទេសនាមថា សព្វថ្ងៃសារមន្ទីរក្រុម "AVG" ខេត្តយូនណានបានបង្កើតកិច្ចសហប្រតិបត្តិការជាមួយសារមន្ទីរអាកាសចរណ៍យោធាជិនណូលត៍នៃប្រទេសអាមេរិក ។ លោកនឹងខិតខំស្វែងរកវត្ថុពិព័រណ៍កាន់តែច្រើនដើម្បីបង្កើតស្ពានមួយខ្សែសម្រាប់តភ្ជាប់ដួងចិត្តរបស់ប្រជាជននៃប្រទេសទាំងពីរ ។

ក្រុម "AVG" ជា "ក្រុមអ្នកបើកយន្តហោះស្ម័គ្រចិត្តអាមេរិក" ដែលដឹកនាំដោយលោកវរសេនីយ៍ឯក ជិនណូលត៍ អតីតយុទ្ធជននៃប្រទេសអាមេរិក ។ ក្រុម "AVG" បានរួមវិភាគទានច្រើនដើម្បីជួយប្រជាជនចិនទទួលបានជោគជ័យក្នុងសង្គ្រាមប្រឆាំងនឹងការឈ្លានពានរបស់ពួកជប៉ុន ។ តាមស្ថិតិ ក្នុងសង្គ្រាមរយៈពេល៧ខែពីឆ្នាំ១៩៤១ដល់ឆ្នាំ១៩៤២ ក្រុម "AVG" បានបាត់បង់យន្តហោះ១២គ្រឿងក្នុងចម្បាំងលើអាកាស ហើយមានយន្តហោះ៦១គ្រឿងត្រូវបាញ់ទម្លាក់ដោយអាវុធលើដីរបស់សត្រូវ តែបានបាញ់ទម្លាក់យន្តហោះសត្រូវជិត៣០០គ្រឿង ។

គួរបញ្ជាក់ថា អ្នកបើកយន្តហោះ២៦ រូបរបស់ក្រុម "AVG" បានពលីជីវិតក្នុងសង្គ្រាមនេះ ៕

# លោក ហី មុំបញ្ញា: ខិតខំពង្រឹងកិច្ចសហប្រតិបត្តិការចិន និងកម្ពុជា

***ដោយ លីវ យ៉ានឈីន***

ពេលថ្មីៗនេះសិក្ខាសាលាស្តីពីសេវាកម្ម និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុប្រទេសកំពុងអភិវឌ្ឍន៍ឆ្នាំ២០១៧ បានប្រារព្ធនៅក្រុងគុនមីង នៃខេត្តយូនណានប្រទេសចិន ។ លោក ហី មុំបញ្ញា អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាបានអញ្ជើញចូលរួមក្នុងសិក្ខាសាលានេះ។ នេះជាលើកទី៣ ដែលលោកបានធ្វើដំណើរមកដល់ក្រុងគុនមីង ដើម្បីចូលរួមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួងពាណិជ្ជកម្មចិន និងមជ្ឈមណ្ឌលផ្លាស់ប្តូរសេដ្ឋកិច្ច និងបច្ចេកទេសអន្តរជាតិខេត្តយូនណាន ។

លោកបានទទួលដំណឹងអំពីសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនេះតាមរយៈស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសកម្ពុជា ។ លោកមានប្រសាសន៍ថា មានប្រជាជនខ្មែរច្រើនចង់ទៅបន្តការសិក្សា និងចូលរួមការផ្លាស់ប្តូរនៅប្រទេសផ្សេងៗ ដើម្បីបង្កើនចំណេះដឹងផ្ទាល់ខ្លួន និងពង្រឹងសមត្ថភាពនៃការធ្វើការងារ ។

ជាការពិតលោកជាសិក្ខាកម្មចាស់មួយរូប ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ៣ឆ្នាំហើយ ។ លោកបានបញ្ជាក់ថាជារៀងរាល់ឆ្នាំម្ចាស់រៀបចំវគ្គបណ្តុះបណ្តាលនេះបានរៀបចំកម្មវិធីសិក្សាយ៉ាងល្អប្រសើរ ដោយមិនគ្រាន់តែបានអញ្ជើញអ្នកជំនាញការល្បីឈ្មោះដែលមានបទពិសោធន៍ច្រើននោះទេ ហើយក៏បានរៀបចំឱ្យសិក្ខាកម្មទៅទស្សនាសហគ្រាសផ្សេងៗ ដើម្បីផ្លាស់ប្តូរទស្សនៈជាមួយអ្នកទទួលខុសត្រូវនៃសហគ្រាសទាំងនោះ ។ វគ្គបណ្តុះបណ្តាលនេះធ្វើឱ្យខ្ញុំទទួលបានផលប្រយោជន៍ដ៏ច្រើន ។

ជាពិសេសលោកចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការប្រែប្រួលរបស់ប្រទេសចិន ។ លោកបន្តទៀតថា សព្វថ្ងៃនៅក្នុងប្រទេសចិនគេអាចបង់ថ្លៃទិញទំនិញគ្រប់ប្រភេទតាមបណ្តាញអ៊ីនធើណេតបាន ហើយក៏អាចជួលកង់តាមផ្លូវតូចធំក្នុងទីក្រុងពិតជាមានភាពងាយស្រួលណាស់ ហើយអាចសំចៃប្រាក់ និងពេលវេលាបាន ។ និស្សិតចិននៅទីនេះអាចទិញបានម្ហូបអាហារ គ្រឿងភេសជ្ជៈ និងសម្ភារៈប្រើប្រាស់តាមបណ្តាញអ៊ីនធើណេត ដោយមិនបាច់ចេញទៅផ្សារ ហើយក៏មិនបាច់បង់ថ្លៃដោយប្រើប្រាស់សាច់ប្រាក់ទេ ។

លោកសង្កត់ធ្ងន់ថា នៅប្រទេសកម្ពុជាគេក៏ចូលចិត្តទិញទំនិញតាមបណ្តាញអ៊ីនធើណេតដែរ ។ មិត្តភក្តិរបស់ខ្ញុំទិញទំនិញតាមវេបសាយ TAOBAO និង ALIBABA ហើយម្ចាស់ហាងនឹងផ្ញើទំនិញនោះទៅប្រទេសកម្ពុជាក្នុងរយៈពេលប្រហែល ២-៣ សប្តាហ៍ ។

នៅពេលនិយាយអំពីកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូររវាងប្រទេសចិន និងកម្ពុជាលោកបានបញ្ជាក់ថា ប្រទេសចិន និងកម្ពុជាបានបង្កើតកិច្ចសហប្រតិបត្តិការក្នុងវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាដើម ។ ខ្ញុំសង្ឃឹមថា ប្រទេសទាំងពីរនឹងអាចពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យហិរញ្ញវត្ថុបច្ចេកទេស និងធនធានមនុស្ស ។ ខ្ញុំនឹងខិតខំប្រឹងប្រែង ដើម្បីរួមចំណែកកាន់តែច្រើនក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងកម្ពុជា ៕

# ខ្លាភាគល្ងាសាននៅសួនសត្វយូនណានកើតកូនភ្លោះ៧

តាមប្រភពព័ត៌មានពីសួនសត្វព្រៃខេត្តយូនណានបានឱ្យដឹងថា ពេលថ្មីៗនេះ សត្វខ្លាភាគល្ងាសានមួយក្បាលដែលចិញ្ចឹមក្នុងសួនសត្វនេះបានកើតកូនភ្លោះ៧ក្បាល ។ ក្រោមការថែរក្សាដោយផ្ចិតផ្ចង់រយៈពេលជិត២ខែ ម្តាយខ្លានិងកូនខ្លាមានសុខភាពយ៉ាងល្អប្រសើរ ។



នេះគឺជាទិដ្ឋភាពដ៏កម្រនៃរូបភាពខ្លាញីផ្តល់កំណើតដល់កូនចំនួន៧ក្បាល (រូបថត: អ្នកថតរូបស៊ីនហួ Jin Huihui )

តាមការឧទ្ទេសនាមបានឱ្យដឹងថា នៅថ្ងៃទី១០ ខែឧសភា ឆ្នាំនេះ កូនខ្លា៧ក្បាលបានកើតនៅក្នុងសួនសត្វព្រៃខេត្តយូនណាន ។ នេះជាលើកទី១ ដែលសត្វខ្លាកើតកូនភ្លោះ៧ក្បាលនៅក្នុងសួនសត្វនេះ ។ គួរបញ្ជាក់ថា ម្តាយខ្លាដែលទើបកើតកូនខ្លានោះមានអាយុ៧ឆ្នាំ ហើយធ្លាប់កើតកូនខ្លា៤ដងម្តងមានកូនខ្លាតែ៣-៤ក្បាល តែពេលនេះកើតកូនខ្លា៧ក្បាល ពិតជារឿងដែលកម្រឃើញណាស់ ។

សួនសត្វព្រៃខេត្តយូនណានមានបច្ចេកទេសចាស់ទុំសម្រាប់បន្តពូជខ្លា ចំណែកកូនខ្លាដែលកើត និងចិញ្ចឹមដោយវិធីបែបមនុស្ស ឬធម្មជាតិក្នុងសួនសត្វនេះ មានអត្រារស់លើសពី៩០ភាគរយ ៕

**(អត្ថបទពីព័ត៌មានស៊ីនហួ ចិន)**